# ជំងឺស្វាយពីកំណើត
## អ្វីដែលអ្នកត្រូវដឹង

Tacoma-Pierce County
Health Department
*Healthy People in Healthy Communities*



**ជំងឺស្វាយគឺជាជំងឺកាមរោគ (STD)។**
អ្នកដែលរួមភេទ—តាមទ្វារមាស ទ្វារធំ ឬដោយប្រើមាត់—គឺអាចឆ្លងជំងឺនេះ។




**អាចនឹងពិបាកសន្និដ្ឋានបានថាតើអ្នកមានជំងឺស្វាយដែរឬអត់។**
វិធីតែមួយគត់ដើម្បីដឹងច្បាស់ គឺត្រូវធ្វើតេស្ត។



**ប្រសិនបើអ្នកធ្វើតេស្តឃើញវិជ្ជមាន សូមទទួលការព្យាបាលភ្លាមៗ។**
ការព្យាបាលជាធម្មតាគឺថ្នាំអង់ទីប៊ីយ៉ូទិច 1 ដូស។
ដៃគូរួមភេទរបស់អ្នកក៏គួរតែទទួលការព្យាបាលដែរ។



**អ្នកមានផ្ទៃពោះអាចចម្លងជំងឺស្វាយទៅកូនក្នុងផ្ទៃរបស់ពួកគេបាន។**
ជំងឺស្វាយដែលកើតលើទារក
ត្រូវបានគេហៅថាជំងឺស្វាយពីកំណើត។



**ទារកដែលកើតមកមានជំងឺស្វាយ ត្រូវតែទទួលការព្យាបាលនៅក្នុងមន្ទីរពេទ្យភ្លាមៗ។**



**នៅពេលដែលអ្នកដឹងថាអ្នកមានផ្ទៃពោះភ្លាម សូមទៅជួបអ្នកផ្តល់សេវាថែទាំសុខភាព។**

ពួកគេនឹងធ្វើតេស្តអ្នករកមើលជំងឺស្វាយ។

ប្រសិនបើអ្នកធ្វើតេស្តឃើញវិជ្ជមាន ពួកគេនឹងព្យាបាលអ្នក។

ការទទួលបានការព្យាបាលអាចបង្ការអ្នកពីការចម្លងជំងឺស្វាយទៅកូនក្នុងផ្ទៃរបស់អ្នក។

**ស្វែងយល់បន្ថែមដោយចូលទៅកាន់ tpchd.org/std ឬទូរសព្ទមកកាន់យើងខ្ញុំតាមរយៈលេខ (253) 649-1418។**